ព្រឹទ្ធសភា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍
# ស្តីពី
# លទ្ធផលការងាររបស់ព្រឹទ្ធសភាប្រចាំខែកុម្ភៈ ឆ្នាំ២០២០

នៅក្នុងខែកុម្ភៈ ឆ្នាំ២០២០នេះ ព្រឹទ្ធសភាបានបំពេញភារកិច្ចដូចតទៅ:

## ១-សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភា

### ១.១ សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា បាន៖

**ក-បដិសណ្ឋារកិច្ចជាមួយភ្ញៀវជាតិ និងអន្តរជាតិ ៖**

-អនុញ្ញាតឱ្យលោកជំទាវ Liurka Rodriguez Barrios ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាព នៃសាធារណរដ្ឋគុយបា ចូលជួបសម្តែងការគួរសម និងសវនាការ

-អនុញ្ញាតឱ្យឯកឧត្តម Pablo Chiho Kang ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាព នៃប្រទេសអូស្ត្រាលី ចូលជួបសម្តែងការគួរសម និងសវនាការ

-ទទួលជួបជាមួយឯកឧត្តម Bounnhang Vorachith ប្រធានរដ្ឋ នៃសាធារណរដ្ឋប្រជាមានិតឡាវ ចូលជួបសម្តែងការគួរសម។

**ខ-សកម្មភាពចូលរួមពិធីផ្សេងៗ ៖**

-អញ្ជើញចូលរួមជាកិត្តិយសក្នុងព្រះរាជពិធីលៀងសាយភោជន៍ជូនឯកឧត្តមអគ្គលេខាធិការមជ្ឈិមបក្សប្រជាជនបដិវត្តន៍ជាតិឡាវ និងជាប្រធានរដ្ឋនៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ និងគណៈប្រតិភូ នៅព្រះបរមរាជវាំង

-អញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងពិធីថ្វាយព្រះភ្លើង ព្រះសពសម្តេចព្រះធម្មលិខិត **លាស់ ឡាយ** សម្តេចព្រះសង្ឃនាយករងទី១ ព្រះប្រធានថេរសភា ព្រះអគ្គាធិការរង ព្រះអនុគណខណ្ឌមានជ័យ និងជាព្រះចៅអធិការវត្តសន្សំកុសល នៅទីលានព្រះមេរុ ខាងមុខវត្តបទុមវតី រាជធានីភ្នំពេញ។

**គ-សកម្មភាពចុះមូលដ្ឋាន ៖**

-អញ្ជើញជួបសំណេះសំណាល និងសាកសួរសុខទុក្ខមន្ត្រីថ្នាក់មូលដ្ឋាន នៅសង្កាត់ព្រែកថ្មី ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ

-អញ្ជើញជួបសំណេះសំណាល និងសាកសួរសុខទុក្ខមន្ត្រីរាជការ កងកម្លាំង នៅសាលា



វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: (855 23) 211 441, 211 442, 211 443 ទូរសារ: (855 23) 211 446, E-mail: oum_sarith@camnet.com.kh

ខណ្ឌកំបូល រាជធានីភ្នំពេញ

-អញ្ជើញជួបសំណេះសំណាល និងសាកសួរសុខទុក្ខប្រជាពលរដ្ឋ កងកម្លាំងមានសមត្ថកិច្ច អាជ្ញាធរសង្កាត់ព្រៃវែង ក្នុងខណ្ឌដង្កោ រាជធានីភ្នំពេញ

-អញ្ជើញជួបសំណេះសំណាល និងសាកសួរសុខទុក្ខប្រជាពលរដ្ឋ កងកម្លាំងមានសមត្ថកិច្ច អាជ្ញាធរសង្កាត់ និងមន្ត្រីថ្នាក់មូលដ្ឋាននៅសង្កាត់ព្រែកលៀប ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ

-អញ្ជើញសាកសួរសុខទុក្ខ បងប្រុស **អ៊ុង ឌឹម** និងភរិយា **ហ៊ុយ ងន់** អតីតយុទ្ធជនយុវនារីភូមិភាគឦសាន ដែលមានជំងឺ និងកំពុងព្យាបាលវះកាត់នៅមន្ទីរពេទ្យកាល់ម៉ែត្រ

-ពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន៩២ច្បាប់ និងជ្រាបជាព័ត៌មានចំនួន៨៨ច្បាប់។

**១.២ ឯកឧត្តម ស៊ឹម កា អនុប្រធានទី១ព្រឹទ្ធសភា បាន :**

**ក-សកម្មភាពចូលរួមពិធីផ្សេងៗ ៖**

-អញ្ជើញជាអធិបតី និងថ្លែងសុន្ទរកថាក្នុងពិធីបើកសន្និសីទអន្តរជាតិ ក្រោមប្រធានបទស្តីពី " ការកសាងខ្សែបន្ទាត់ព្រំដែន សន្តិភាពមិត្តភាពកម្ពុជា-ឡាវ " ។

**ខ-ការចូលរួមសិក្ខាសាលា វេទិកា និងកិច្ចប្រជុំនានា ៖**

-អញ្ជើញជាអធិបតីក្នុងពិធីពិសាអាហារសាមគ្គីទទួលស្វាគមន៍គណៈប្រតិភូជាន់ខ្ពស់គណៈកម្មាធិការមជ្ឈិមរណសិរ្សអភិវឌ្ឍន៍ជាតិឡាវ ដឹកនាំដោយឯកឧត្តម **ខាំបៃ ដាំឡាក់** សមាជិកមជ្ឈិមបក្សប្រជាជនបដិវត្តន៍ជាតិឡាវ និងជាអនុប្រធានគណៈកម្មាធិការមជ្ឈិមរណសិរ្សអភិវឌ្ឍន៍ជាតិឡាវ ស្ថិតនៅក្នុងក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង

-ពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗ និងជ្រាបជាព័ត៌មានចំនួន៣៥ច្បាប់។

**១.៣.ឯកឧត្តម ទេព ងន អនុប្រធានទី២ ព្រឹទ្ធសភា បាន :**

**ក-សកម្មភាពចុះមូលដ្ឋាន ៖**

-អញ្ជើញដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្ត មកពីប្រទេសបារាំងទៅពិនិត្យ និងព្យាបាលជំងឺជូនប្រជាពលរដ្ឋនៅឃុំបារ៉ុង ស្រុកល្វាឯម ខេត្តកណ្តាល ព្រមទាំងឧបត្ថម្ភលើការចំណាយដល់អ្នកជំងឺឈឺធ្ងន់ម្នាក់ ដើម្បីបានទៅពិនិត្យ និងព្យាបាលជំងឺនៅមន្ទីរពេទ្យជោរីភ្នំពេញ

-អញ្ជើញជួបសំណេះសំណាលជាមួយអាជ្ញាធរស្រុក យាយជី តាជី និងព្រះសង្ឃ

ព្រមទាំងពិនិត្យមើលសមិទ្ធផលនានាក្នុងវត្ត ដែលទើបសាងសង់រួច នៅវត្តសុវណ្ណារ៉ាម ហៅវត្តទួលអង្គ ស្ថិតនៅភូមិក្រាំងស្តៅ ឃុំសឹង ស្រុកសំរោង ខេត្តតាកែវ។

**ខ-សកម្មភាពចូលរួមពិធីផ្សេងៗ៖**

-អញ្ជើញចូលរួមពិធីរាប់បាត្រព្រះសង្ឃ៧២អង្គ និងចែកអំណោយជូនយាយជី តាជី នៅវត្តប្រាំបីមុំ ស្ថិតក្នុងឃុំប្រាំបីមុំ ស្រុកទ្រាំង ខេត្តតាកែវ

-អញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីជប់លៀងជូនគណៈប្រតិភូឡាវ នៅសណ្ឋាគារសូហ្វីតែលភ្នំពេញ

-អញ្ជើញពិសាអាហារសាមគ្គីជាមួយក្រុមសមាជិកាព្រឹទ្ធសភា នៅភោជនីយដ្ឋានបាណាណាលីវ ស្ថិតក្នុងផ្សារទំនើបជីបម៉ុងឡូរ៉ម៉ល

-ពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន៤៥ច្បាប់ និងជ្រាបជាព័ត៌មានចំនួន១២ច្បាប់។

## ២.គណៈកម្មការជំនាញនានារបស់ព្រឹទ្ធសភា :

ក្នុងខែកុម្ភៈនេះ សមាជិក សមាជិកាព្រឹទ្ធសភា បានបំពេញការងារយ៉ាងសកម្មតាមតួនាទី ភារកិច្ច និងសមត្ថកិច្ចរបស់ខ្លួនប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ដូចខាងក្រោមៈ

### ២.១ មុខងារតាមដានការអនុវត្តច្បាប់ និងគោលនយោបាយនានា

-អញ្ជើញចុះបេសកកម្ម ដើម្បីឈ្វេងយល់អំពីការអនុវត្តច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ ការអនុវត្តកំណែទម្រង់វិមជ្ឈការ និងការអភិវឌ្ឍមូលដ្ឋាន នៅខេត្តប៉ៃលិន និងខេត្តបន្ទាយមានជ័យ

-អញ្ជើញចុះបេសកកម្ម ដើម្បីឈ្វេងយល់អំពីការវិវត្តរីកចម្រើនថ្មី និងបញ្ហាប្រឈមរបស់ខេត្ត និងវិស័យពាក់ព័ន្ធនឹងសមត្ថកិច្ចរបស់គណៈកម្មការ នៅខេត្តកំពង់ឆ្នាំង ខេត្តពោធិ៍សាត់ និងខេត្តបាត់ដំបង។

### ២.២ មុខងារតំណាង

-បានទទួលពាក្យបណ្តឹងចំនួន០៦ករណី ធ្វើលិខិតអន្តរាគមន៍ទៅក្រសួង ស្ថាប័នពាក់ព័ន្ធដើម្បីដោះស្រាយបានចំនួន០៩ករណី ទទួលលិខិតឆ្លើយតបអំពីការដោះស្រាយពីក្រសួង ស្ថាប័នពាក់ព័ន្ធចំនួន០១ករណី កំពុងពិនិត្យសិក្សាចំនួន០៤ករណី ព្រមទាំងទទួលឯកសារពាក្យបណ្តឹងដែលក្រសួង ស្ថាប័នពាក់ព័ន្ធចម្លងជូនមកគណៈកម្មការដើម្បី ជូនជ្រាបចំនួន០៦ករណី។

-បានរៀបចំវេទិកាសាធារណៈថ្នាក់ខេត្តស្តីពី " ការអនុវត្តតួនាទី ភារកិច្ចក្រុមប្រឹក្សា

ឃុំ និងសហការផ្តល់សេវាសាធារណៈ ព្រមទាំងការអភិវឌ្ឍមូលដ្ឋាន ” នៅខេត្តកំពង់ចាម

-អញ្ជើញជួបពិភាក្សាការងារជាមួយឯកឧត្តម **វេង សាខុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីដោះស្រាយបញ្ហាប្រឈមមួយចំនួនរបស់កសិករខ្នាតតូច មធ្យម និងខ្នាតធំ និងនាំយកបញ្ហាប្រឈម និងសំណូមពររបស់ពួកគាត់ដាក់ស្នើសុំទៅប្រមុខរាជរដ្ឋាភិបាល ដើម្បីជួយរកដំណោះស្រាយ

-សមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៨ បានប្រជុំដើម្បីត្រៀមរៀបចំពិធីបុណ្យបញ្ចុះសីមា នៅស្រុកសៀមប៉ាង ខេត្តស្ទឹងត្រែង

-អញ្ជើញចូលរួមប្រជុំ ដើម្បីត្រៀមរៀបចំវេទិការាជរដ្ឋាភិបាល ជាមួយផ្នែកឯកជន លើកទី១៩ ដោយមានការចូលរួមពីសហប្រធានក្រុមការងារទាំង១៣ ផ្នែកឯកជន នៃវេទិការាជរដ្ឋាភិបាល-ឯកជន (G-PSF)

-អញ្ជើញចូលរួមប្រជុំជាមួយក្រុមប្រឹក្សាសង្កាត់ទាំង១០ នៃខណ្ឌទួលគោក រាជធានី-ភ្នំពេញ ដើម្បីពិនិត្យលទ្ធផលការអនុវត្តគោលនយោបាយភូមិ ឃុំ មានសុវត្ថិភាព និងលើកទិសដៅបង្កើនប្រសិទ្ធភាពការងារ បម្រើសេវាជូនប្រជាពលរដ្ឋនៅមូលដ្ឋាន លើការងារសណ្តាប់ធ្នាប់សាធារណៈ ការងារគ្រប់គ្រងដឹកជញ្ជូន និងបង់ថ្លៃសំរាមតាមគោលការណ៍ថ្មីរបស់សាលារាជធានីភ្នំពេញ

-អញ្ជើញចូលរួមប្រជុំជាមួយប្រធានភូមិទាំង១៣ នៃក្រុមប្រឹក្សាសង្កាត់ទឹកល្អក់ទី២ ស្តីពីការងាររួមគ្នាថែទាំសុខភាពបង្ការទប់ស្កាត់ជំងឺឆ្លងវិរុស កូរ៉ូណា បង្កើនសកម្មភាពសមាគមមនុស្សចាស់ ចុះផ្សព្វផ្សាយតាមខ្នងផ្ទះប្រជាពលរដ្ឋឱ្យយល់ដឹង និងសហការបង់ថ្លៃសេវាសំរាមស្របតាមគោលការណ៍ថ្មី

-អញ្ជើញជួបពិភាក្សាការងារជាមួយក្រុមប្រឹក្សាសង្កាត់បឹងធំ ដើម្បីណែនាំ និងជម្រុញអំពីការរៀបចំបញ្ជីឈ្មោះបោះឆ្នោតតាមភូមិនីមួយៗ ព្រមទាំងបានអញ្ជើញប្រគល់អណ្តូងទឹកស្អាតចំនួន០២ ដែលជាអំណោយរបស់ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី១ស្ថិតក្នុងវិទ្យាល័យបឹងធំ និងសាលាបុណ្យភូមិក្រោក ស្ថិតក្នុងសង្កាត់បឹងធំ ខណ្ឌកំបូល រាជធានី-ភ្នំពេញ

-អញ្ជើញចូលរួមជាវាគ្មិនកិត្តិយស ដើម្បីចែករំលែកបទពិសោធន៍ដល់សិស្ស និស្សិត ស្តីពី “ ការចាប់ផ្តើមអាជីវកម្មដំបូងត្រូវយល់ដឹងអ្វីខ្លះ”

-អញ្ជើញចូលរួមសិក្ខាសាលាបញ្ចប់គម្រោងកម្មវិធីចែកវិញ្ញាបនបត្រ និងពិធីប្រគល់ឯកសារបណ្តុះបណ្តាលស្តីពី “ ការវិភាគសារពើពន្ធ (FACT Program) ការិយាល័យសភា(PBO)

-អញ្ជើញចូលរួមសន្និបាតបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០១៩ និងទិសដៅការងារ

ឆ្នាំ២០២០ របស់សមាគមនារីកម្ពុជា ដើម្បីសន្តិភាព និងអភិវឌ្ឍន៍ នៅរាជធានីភ្នំពេញ

-អញ្ជើញសម្ពោធអណ្តូងទឹកស្អាតចំនួន០៥កន្លែង នៅឃុំត្រពាំងថ្ម ឃុំឃុនរាម ស្រុកបន្ទាយស្រី ខេត្តសៀមរាប

-អញ្ជើញសំណេះសំណាល និងដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តរបស់សមាគមបេសកកម្មសិក្សាអាស៊ី(AMS) ប្រទេសបារាំង ចុះពិនិត្យ និងព្យាបាលជំងឺជូនប្រជាពលរដ្ឋ នៅឃុំព្រៃទឹង ស្រុកស៊ីធរកណ្តាល ខេត្តព្រៃវែង

-អញ្ជើញចូលរួមស្តាប់បទបង្ហាញ និងពិភាក្សាការងារត្រៀមរៀបចំកិច្ចប្រជុំ (ASEP) លើកទី១១ ជាមួយលោក **នីកូឡូ វីណាឌីល** ប្រធានអង្គភាពគោលនយោបាយក្រៅប្រទេសនៃសភាអឺរ៉ុបប្រចាំក្រុងប្រ៊ុចសែល និងលោកជំទាវ **កាមេន ម៉ូរីណូ** ឯកអគ្គរដ្ឋទូតសហភាពអឺរ៉ុបប្រចាំនៅព្រះរាជាណាចក្រកម្ពុជា

សមាជិក សមាជិកាព្រឹទ្ធសភា បានអញ្ជើញចុះទៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្តក្រុងចំនួន១០០លើក ដើម្បីជួបពិភាក្សាការងារ សំណេះសំណាល សាកសួរសុខទុក្ខប្រជាពលរដ្ឋ សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តចុះពិនិត្យ និងព្យាបាលជំងឺជូនប្រជាពលរដ្ឋ ពិនិត្យការដ្ឋានសាងសង់ សម្ពោធសមិទ្ធផលនានា តាមដានការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ក្រោមជាតិ ការអនុវត្តគោលនយោបាយភូមិ ឃុំ មានសុវត្ថិភាព សិក្សាឈ្វេងយល់អំពីស្ថានភាពសិទ្ធិមនុស្ស ការអនុវត្តច្បាប់ កែលម្អសេវាសាធារណៈ ពង្រឹងអភិបាលកិច្ចល្អនៅមូលដ្ឋាន និងគោលនយោបាយផ្សេងៗលើគ្រប់វិស័យ ព្រមទាំងបានចូលរួមក្នុងពិធីផ្លូវការ និងពិធីផ្សេងៗសរុបចំនួន៦៩លើក។ ✍

ថ្ងៃចន្ទ ១រោច ខែផល្គុន ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ, ថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២០

**ជ.ប្រធានព្រឹទ្ធសភា**

**អនុប្រធានទី២**

**ទេព ងន**

*ចម្លងជូន:*

- *ក្រសួងព្រះបរមរាជវាំង*
- *ក្រុមប្រឹក្សាធម្មនុញ្ញ*
- *ទីស្តីការគណៈរដ្ឋមន្ត្រី*
- *ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ*
- *ក្រសួងយុត្តិធម៌*
- *ក្រសួងព័ត៌មាន*
- *(ទូលថ្វាយ និងជូនជ្រាបជាព័ត៌មាន)*
- *កាលប្បវត្តិ-ឯកសារ*